ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

_សំណុំរឿងរដ្ឋប្បវេណី
លេខ: ៨២៩
ចុះថ្ងៃទី ១៩.១០.២០១៩
_សាលក្រមលេខ: ២៩ (ឌ)
ចុះថ្ងៃទី ១១.១២.២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១០ ព្រឹក ប្រកាសសាលក្រមនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម:

_ដើមចោទឈ្មោះ [redacted] សម្បត្តិ ភេទស្រី អាយុ ៧៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

-អ្នកតំណាងដោយអាណត្តិ: លោកស្រីមេធាវី [redacted] និងលោកស្រី [redacted] ។

_និងចុងសហចម្លើយ:

១-ឈ្មោះ [redacted] សុបញ្ញា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

២-ឈ្មោះ [redacted] មុន្នី ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

៣-ឈ្មោះ [redacted] ស្រី ភេទស្រី អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

-អ្នកតំណាងដោយអាណត្តិ: លោកមេធាវី [redacted] ។

**កម្មវត្ថុបណ្តឹង:**

១-សុំឱ្យតុលាការទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនិងផ្ទះលេខ៧៩ក្រុមទី៨ភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ដែលមានបណ្តោយប្រវែង ១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រ ។

២-សុំឱ្យហាមឃាត់មិនឱ្យធ្វើការប៉ះពាល់ចេញចូលស្នាក់នៅអាស្រ័យផល ទិញលក់ ជួលបញ្ចាំ ធ្វើអច្ច័យទាន ផ្ទេរសិទ្ធិ ឬធ្វើសកម្មភាពផ្លូវច្បាប់ណាមួយទៅលើផ្ទះ និងដីមានទីតាំងស្ថិតនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ដែលមានបណ្តោយប្រវែង ១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់និង [redacted] សម្បត្តិ ខាងត្បូងទល់និង [redacted] សារី ខាងកើតទល់និងផ្លូវរទេះ ខាងលិចទល់និងចំណីផ្លូវ ដែលមានលិខិតបញ្ជាក់ពីប្រវត្តដីធ្លីចេញដោយសាលាឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល លេខ៣៥៨/១៩



Scanned with CamScanner

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលបញ្ជាក់ ថាពិតជាដីរបស់ឈ្មោះ [redacted] សម្បត្តិ ភេទស្រីអាយុ ៧៧ឆ្នាំ មានទីលំនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ។

៣សុំឱ្យចុះចេញពីផ្ទះនិងរុះរើចេញនូវទ្រព្យសម្បត្តិទាំងឡាយណាដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុបញ្ញា ,ឈ្មោះ [redacted] មុន្នី ( [redacted] មុន្នី) និង [redacted] ស្រី ពីលើទីតាំងដីនិងផ្ទះខាងលើតាមដីកាសម្រេចលេខៈ៨៨ដក.សរ/១៩ ចុះថ្ងៃទី០៩_ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល ។

៤-ម្ចាស់បំណុល [redacted] សម្បត្តិ ស្នើសុំរុះរើផ្ទះចាស់នេះចេញដោយម្ចាស់បំណុលខ្លួនឯង ។

៥-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ។

៦-ទាមទារប្រាក់សំណងជម្ងឺចិត្តការខាតបង់ពេលវេលានិងចំណាយសេវាកម្មច្បាប់សរុបជាទឹក ប្រាក់ចំនួន ៥០លានរៀល (ហាសិបលានរៀលគត់) ។

_បានឃើញពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] សម្បត្តិ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៩ ។

_បានឃើញសៀវភៅគ្រួសាររបស់ឈ្មោះ [redacted] សម្បត្តិ No ០៩.៥៣១៣ ក.ណ ។

_បានឃើញសៀវភៅស្នាក់នៅនាមត្រកូល-នាមខ្លួន [redacted] សម្បត្តិ លេខ ០០៦.១២៣៨ ។

_បានឃើញលិខិតបញ្ជាក់ពីប្រវត្តដីធ្លី ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល លេខ ៣៥៨/១៩ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ។

_បានឃើញដីកាសម្រេចលេខៈ ៨៨ ដក.សរ/១៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល ។

## អង្គហេតុ និងចំណុចវិវាទ

**១/ ខ្លឹមសារនៃការទាមទារដោយដើមចោទ**

**ដើមចោទប្ដឹងសុំឱ្យតុលាការចេញសាលក្រមដូចតទៅៈ**

១-សុំឱ្យតុលាការទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះលេខ ៧៩ ក្រុមទី៨ ភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ដែលមានបណ្ដោយប្រវែង១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រ ។

២-សុំឱ្យហាមឃាត់មិនឱ្យធ្វើការប៉ះពាល់ចេញចូល ស្នាក់នៅអាស្រ័យផលទិញលក់ ជួល បញ្ចាំ ធ្វើអច្ច័យទាន ផ្ទេរសិទ្ធិ ឬធ្វើសកម្មភាពផ្លូវច្បាប់ណាមួយទៅលើផ្ទះ និងដីមានទីតាំងស្ថិតនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ដែលមានបណ្ដោយប្រវែង ១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រ មានព្រំប្រទល់ខាង ជើងទល់និង [redacted] សម្បត្តិ ខាងត្បូងទល់និង [redacted] សារី ខាងកើតទល់និងផ្លូវរទេះ ខាងលិចទល់និងចំណីផ្លូវ ដែលមានលិខិតបញ្ជាក់ពីប្រវត្តិដីធ្លីចេញដោយសាលាឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល លេខ ៣៥៨/១៩ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលបញ្ជាក់ថាពិតជាដីរបស់ឈ្មោះ [redacted] សម្បត្តិ ភេទស្រី អាយុ ៧៧ឆ្នាំ មានទីលំនៅ [redacted] ។

៣-សុំឱ្យចុះចេញពីផ្ទះនិងរុះរើចេញនូវទ្រព្យសម្បត្តិទាំងឡាយណាដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុបញ្ញា,ឈ្មោះ [redacted] មុន្នី ( [redacted] មុន្នី) និងឈ្មោះ [redacted] ស្រី ពីលើទីតាំងដី និងផ្ទះខាងលើតាមដីកាសម្រេចលេខៈ ៨៨ ដក.សរ/១៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល ។

៤-ម្ចាស់បំណុល [redacted] សម្បត្តិ ស្នើសុំរុះរើផ្ទះចាស់នេះចេញដោយម្ចាស់បំណុលខ្លួនឯង ។

៥-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន។

៦-ទាមទារប្រាក់សំណងជម្ងឺចិត្តការខាតបង់ពេលវេលា និងចំណាយសេវាកម្មច្បាប់សរុបជាទឹកប្រាក់ចំនួន ៥០លានរៀល (ហាសិបលានរៀលគត់) ។



Scanned with CamScanner

## ២/ ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

ដើមចោទឈ្មោះ [redacted] សម្បត្តិ មានទីលំនៅបច្ចុប្បន្ននៅ[redacted] ឈ្មោះ [redacted] មុន្នី ([redacted] សុមុន្នី) បានមករស់នៅជាមួយខ្លួនតាំងពីតូច លុះដល់មានអាយុ ១៦ឆ្នាំក៏បានរៀបការហើយបានចាកចេញពីផ្ទះនៅឆ្នាំ១៩៨៧ ទៅរស់នៅភូមិផ្សេង ជាមួយប្រពន្ធរហូតដល់បច្ចុប្បន្ន ។ ក្នុងកំឡុងឆ្នាំ២០១១ ឈ្មោះ [redacted] សុបញ្ញា ជាកូនរបស់ [redacted] មុន្នី និងប្រពន្ធព្រមទាំងកូនស្រីតូចៗពីរនាក់ ក៏បានមករស់នៅជាមួយខ្លួននៅ[redacted] លើដីដែលមានទំហំបណ្តោយប្រវែង ១៦២ម៉ែត្រ ទទឹង ២៩ម៉ែត្រ។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ ខ្លួនបានជួលជាងឱ្យរុះរើផ្ទះចាស់របស់ខ្លួនចោល ដោយបានជូនដំណឹងមុនទៅឈ្មោះ [redacted] សុបញ្ញា ដែលជាអ្នកកំពុងស្នាក់អាស្រ័យ ២សប្តាហ៍ដោយគាត់បានដឹងរួចមកហើយមុននិងធ្វើការរុះរើនេះ តែឈ្មោះ [redacted] មុន្នី និងឈ្មោះ [redacted] សុបញ្ញា មិនព្រមឱ្យជាងរុះរើឡើយ ហើយថែមទាំងគម្រាមថា បើអ្នកណាហ៊ានឡើងរុះប្រយ័ត្នគ្រោះថ្នាក់(ដោយដៃកំពុងកាន់កាំបិតខ្វារ) បន្ទាប់មកខ្លួនក៏បានឡើងលើផ្ទះ ហើយបានហៅជាងឱ្យឡើងមកជាមួយតែជាងមិនមាននរណាហ៊ានឡើងទេ ។ ដោយខ្លួនខ្លាចមានគ្រោះថ្នាក់ទើបខ្លួនបានយករបស់របរប្រើប្រាស់របស់ខ្លួនបន្តិចបន្តួចចុះមកវិញហើយក៏បានចាកចេញពីផ្ទះចាប់ពីពេលនោះមក ។ លុះដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ទើបខ្លួនបានដាក់ពាក្យបណ្តឹងសុំឱ្យតុលាការទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនិងផ្ទះលេខ៧៩ ក្រុម៨ ភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ។

## ៣.ការអះអាងរបស់គូភាគី

### ៣.១.ការអះអាងរបស់ដើមចោទ

_ដើមចោទឈ្មោះ [redacted] **សម្បត្តិ** បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនបានរស់នៅតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះដោយនៅជាមួយបងប្អូនតែគាត់ស្លាប់អស់ហើយ ។ ឯសហចុងចម្លើយត្រូវជាក្មួយ របស់ខ្លួនបានមករស់នៅជាមួយខ្លួនតាំងពីអាយុ ៣ទៅ៤ឆ្នាំមកម្ល៉េះ គឺខ្លួនបានចិញ្ចឹមតាំងពីឪរហូតដល់កូននិងបានចែកដីឱ្យនៅ ទៀត ហើយការដែលមករស់នៅជាមួយខ្លួនតាំងពីឆ្នាំណានោះគឺខ្លួនមិនបានចាំទេ ។ បច្ចុប្បន្នខ្លួនបានទៅមកផ្ទះនោះជាធម្មតាទេ ។ ខ្លួនបានចែកដីឱ្យទៅឈ្មោះ [redacted] ម៉ន តែស្លាប់អស់ហើយ ក្រោយមកខ្លួនបានរៀបការប្រពន្ធឱ្យឈ្មោះ [redacted] មុន្នី និងបានចែករបបឱ្យទៅឪពុក [redacted] មុន្នី នៅភូមិផ្សេងរួចហើយ ។ [redacted] មុន្នី បានទៅរស់នៅភូមិផ្សេង ហើយក៏មិនដែលត្រឡប់មករស់នៅវិញដែរ ចំណែកឯកូនរបស់ [redacted] មុន្នី គឺឈ្មោះ [redacted] សុបញ្ញា គឺបានមករស់នៅជាមួយខ្លួន តែមករស់នៅក្នុងឆ្នាំណាគឺខ្លួនមិនាចាំទេ ។ ចំពោះឈ្មោះ [redacted] សុបញ្ញា មករស់នៅជាមួយខ្លួនគឺខ្លួន បានជួលឱ្យមកធ្វើចំការអោយនិងរស់នៅគ្រាន់បានជាគ្នាតែប៉ុណ្ណោះ។ បញ្ហាដែលខ្លួនចេញពីផ្ទះនោះគឺខ្លួនមកព្យាបាលជម្ងឺ ។

### ៣.២.ការអះអាងរបស់សហចុងចម្លើយ

_ឈ្មោះ [redacted] **មុន្នី** ជាចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនបានរស់នៅជាមួយ ឈ្មោះ [redacted] សម្បត្តិ តាំងពីឆ្នាំ១៩៧៩ ជាមួយតាម៉ឹង យាយអ៊ំ ជាបងប្អូនគាត់តែឪពុកខ្លួនបានស្លាប់ហើយ ។ ពេលនោះគឺរដ្ឋថាអ្នកណាចាប់បានប៉ុណ្ណាយកប៉ុណ្ណឹងទៅហើយពេលនោះខ្លួនអាយុប្រហែល ១៥ឆ្នាំហើយ ។ តែពេលនៅឪពុកខ្លួនមិនបានរស់នៅលើដីទំនាស់នេះទេ ខ្លួនបានមករស់នៅឯស្រែជាមួយឈ្មោះ [redacted] សម្បត្តិ ហើយខ្លួនបានការប្រពន្ធនៅឆ្នាំ១៩៨៧ ទៅនៅភូមិផ្សេងហើយការរស់នៅ លើដីនេះពុំមានលិខិតស្នាមអ្វីទេតែដោយខ្លួនយល់ថាគាត់ជាមីង ។ ខ្លួនមិនបានធ្វើប័ណ្ណដីទេ ព្រោះកាលនោះមិនមានគេចុះទៅធ្វើទេ ។ ខ្លួនរស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ តាំងពីឆ្នាំ១៩៧៩ តែមិនបានចុះឈ្មោះនៅក្នុងប័ណ្ណគ្រួសារទេ ។ រដ្ឋចែកដីឱ្យនៅឆ្នាំ១៩៨០ គឺ

ពេលនោះខ្លួនអាយុប្រហែល ១៤ឆ្នាំ តែឱ្យតែអ្នកនៅសុទ្ធតែមានរបបទាំងអស់ ។ ក្នុងឆ្នាំ១៩៨៧ ដែលខ្លួនទៅរស់នៅជាមួយប្រពន្ធគឺ ដីរដ្ឋចែកឱ្យសុទ្ធ ។

_ឈ្មោះ [redacted] **សុបញ្ញា** ជាសហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនមករស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ នេះគឺគាត់បានសុំខ្លួនឱ្យមករស់នៅជាមួយគាត់ តែខ្លួនមិនទាន់មានប្រពន្ធទេ ។ ចំពោះចំណែកដីនេះគឺខ្លួនគ្មានទេគឺចាស់ៗបានមាន ។

**៣.៣.ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទៈ**

_លោកស្រីមេធាវី [redacted] និងលោកស្រី [redacted] បានធ្វើសេចក្តីថ្លែងការថាៈ ខ្លួននៅតែរក្សាចម្លើយតាមពាក្យ បណ្តឹងចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ទុកជាបានការដដែលដោយពុំ មានការកែប្រែឡើយ ។ ដើមចោទគឺជាម្ចាស់កម្មសិទ្ធិករលើដីខាងលើដោយបានធ្វើការកាន់កាប់ជាក់ស្តែងតាំងពីឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្នដោយមានលិខិតបញ្ជាក់ពីប្រវត្តដីធ្លីពីអាជ្ញាធរមានសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ និងមានសាក្សីដែលអាចបញ្ជាក់បានថាដើមចោទពិតជាម្ចាស់កម្មសិទ្ធិករពិតប្រាកដមែន ម្យ៉ាងវិញទៀតកំណត់ហេតុស្តីពីការសួរភាគីដែលជាសហចុងចម្លើយកាលពីថ្ងៃទី២១ខែសីហា ឆ្នាំ២០១៩ នៅចំពោះមុខសាលាដំបូងខេត្តកណ្តាល សហចុងចម្លើយទាំងបីនាក់បានឆ្លើយទទួលស្គាល់ថាដីខាងលើនេះគឺពិតជារបស់ឈ្មោះ [redacted] សម្បត្តិ ជាដើមចោទពិតប្រាកដមែន ។ មេធាវីដើមចោទបានបញ្ជាក់ បន្ថែមថាសហចុងចម្លើយឈ្មោះ [redacted] មុន្នី និងប្រពន្ធឈ្មោះ [redacted] ស្រី គឺបានចាកចេញពីដីនិងផ្ទះខាងលើតាំងពីឆ្នាំ១៩៨៧ និងមានអាសយដ្ឋាននៅភូមិចុងកោះ រហូតដល់បច្ចុប្បន្នហើយចុងចម្លើយឈ្មោះ [redacted] សុបញ្ញា ទើបតែមកសុំដើមចោទស្នាក់នៅជាមួយកាលពីឆ្នាំ២០១១ ហើយដើមចោទមិនដែលបានធ្វើការផ្ទេរកម្មសិទ្ធិលើដីនេះឱ្យទៅសហចុងចម្លើយនោះទេ ។ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ ផ្ទះរបស់ដើមចោទត្រូវបានចាក់សោរដោយដើមចោទមិនអាច ចេញចូលនិងស្នាក់នៅដូចពីមុនទៀតបានដោយផ្ទះត្រូវចាក់សោរនិងកាន់កាប់ដោយសហចុងចម្លើយ ដោយមានការព្រួយបារម្ភថាដើមចោទអាចបាត់បង់សិទ្ធិក្នុងការកាន់កាប់និងគ្រប់គ្រងដីខាងលើ ទើបខ្លួនស្នើសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្នដូចខាងលើ ។ ចំពោះសំណងជម្ងឺចិត្តការខូចខាតបង់ពេលវេលា ដើមចោទស្នើសុំឱ្យតុលាការបង្គាប់ឱ្យសហចុងចម្លើយបងជាប្រាក់ចំនួន ៥០លានរៀល (ហាសិបលានរៀល) ដោយហេតុថាសហចុងចម្លើយឈ្មោះ [redacted] សុបញ្ញា និង [redacted] មុន្នី ធ្លាប់ធ្វើឱ្យមានការបាត់បង់ប្រាក់របស់ដើមចោទចំនួនពីម៉ឺនប្រាំពាន់ដុល្លារ និងធ្លាប់ធ្វើការបន្លំប្រាក់របស់ដើមចោទចំនួនប្រាំពាន់ដុល្លារ ពាក់ព័ន្ធនិងផ្នែកស្មារតីដោយសារដើមចោទមានវ័យចាស់ជរាខ្លាចមានការប៉ះពាល់ដល់រាងកាយ និងអាយុជីវិត និងមានការថែទាំផ្នែកសុខភាពដោយចុងចម្លើយ ឈ្មោះ [redacted] សុបញ្ញា និងប្រពន្ធកំពុងរស់នៅលើផ្ទះរបស់ដើមចោទ ឯដើមចោទបែរជាត្រូវចាកចេញទៅរស់នៅកន្លែងផ្សេង ។

**៣.៤.ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ**

_លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនសុំបដិសេធនូវចំណុចទី១ នៃការទាមទាររបស់មេធាវីដើមចោទដោយមូលហេតុថាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] មុន្នី បានមករស់នៅជាមួយដើមចោទតាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៨៧ ទើបកូនក្តីខ្លួនបានរៀបការនិងចាកចេញពីផ្ទះរបស់ដើមចោទ ។ ប៉ុន្តែក្នុងកំឡុងឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៨០ រដ្ឋបានធ្វើការចុះបែងចែកដីជូនប្រជាពលរដ្ឋក្នុងភូមិកំពង់រទេះ តាមគ្រួសារនីមួយៗនិងបែងចែកតាមសមាជិកគ្រួសារ ។ ការបែងចែកដីនេះរដ្ឋបានបែងចែកដីចំនួនប្រាំកន្លែង ដែលនៅក្នុងនោះមានដីលំនៅដ្ឋានដែលដើមចោទធ្វើការទាមទារឱ្យតុលាការទទួលស្គាល់សិទ្ធលើដីនោះ ក៏មានចំណែករបស់កូនក្តីខ្លួនដែរ ។ ហើយខ្លួនសុំបដិសេធចោលនូវចំណុចទីពីរនៃការទាមទាររបស់មេធាវីដើមចោទ ដោយហេតុថាកម្មសិទ្ធិនៃដីខាងលើ គឺមានចំណែកកូនក្តីខ្លួនដូច្នេះខ្លួនសុំបដិសេធចោលរហូតដល់មានសេចក្តីសម្រេចណាមួយ



Scanned with CamScanner

ចេញពីតុលាការ ។ សុំច្រានចោលនូវការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ដោយសារការអនុវត្តនេះធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កូនក្តីខ្លួនធ្ងន់ធ្ងរ ។ ចំណែកឯចំណុចទី៤ការទាមទារជម្ងឺចិត្តរបស់ដើមចោទ ដោយមូលហេតុដើមចោទបានធ្វើការចោទប្រកាន់កូនក្តីខ្លួនធ្វើឱ្យបាត់បង់ប្រាក់របស់ដើមចោទចំនួនពីម៉ឺនប្រាំពាន់ដុល្លារ និងធ្លាប់ធ្វើការបន្តប្រាក់របស់ដើមចោទចំនួនប្រាំពាន់ដុល្លារដោយគ្មានមូលដ្ឋានច្បាស់លាស់ដូច្នេះគម្បីតុលាការច្រានចោលនូវចំណុចនេះទាំងស្រុង ។

៤. ចំណុចវិវាទៈ

១-សុំឱ្យតុលាការទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះលេខ ៧៩ ក្រុមទី៨ ភូមិកំពង់រទេះ ឃុំកោះ ចិន ស្រុកពញាឮ ខេត្តកណ្តាល ដែលមានបណ្តោយប្រវែង១៦០ម៉ែត្រ និងទទឹងប្រវែង២៨,៧ម៉ែត្រ ។

២-សុំឱ្យចុះចេញពីផ្ទះ និងរុះរើចេញនូវទ្រព្យសម្បត្តិទាំងឡាយណាដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុបញ្ញា ,ឈ្មោះ [redacted] មុន្នី ([redacted] មុន្នី) និង [redacted] ស្រី ពីលើទីតាំងដី និងផ្ទះខាងលើតាមដីកាសម្រេចលេខៈ៨៨ ដក.សរ/១៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ។

៥-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

៦-ទាមទារប្រាក់សំណងជម្ងឺចិត្តការខាតបង់ពេលវេលា និងចំណាយសេវាកម្មច្បាប់សរុបជាទឹកប្រាក់ចំនួន ៥០លានរៀល (ហាសិបលានរៀលគត់) ។

## សាលាដំបូងខេត្តកណ្តាល

## សំអាងហេតុ

១-មូលហេតុដែលបានលើកឡើងក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាបាន ។

២-នៅក្នុងនីតិវិធីត្រៀម ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថាៈ

២-១.ដើមចោទបានអះអាងថាខ្លួនបានរស់នៅតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ដោយនៅជាមួយបងប្អូនតែគាត់ស្លាប់អស់ហើយ ។ ឯសហចុងចម្លើយត្រូវជាក្មួយរបស់ខ្លួនបានមករស់នៅជាមួយខ្លួនតាំងពីអាយុ ៣ ទៅ ៤ឆ្នាំមកម្ល៉េះគឺខ្លួនបានចិញ្ចឹមតាំងពីឪរហូតដល់កូននិងបានចែកដីឱ្យនៅទៀត ហើយការដែលមករស់នៅជាមួយខ្លួនតាំងពីឆ្នាំណានោះគឺខ្លួនមិនបានចាំទេ ។ បច្ចុប្បន្នខ្លួនបានទៅមកផ្ទះនោះជាធម្មតាទេ ។ ខ្លួនបានចែកដីឱ្យទៅឈ្មោះ [redacted] ម៉ន តែស្លាប់អស់ហើយ ក្រោយមកខ្លួនបានរៀបការប្រពន្ធឱ្យឈ្មោះ [redacted] មុន្នី និងបានចែករបបឱ្យទៅឪពុក [redacted] មុន្នី នៅភូមិផ្សេងរួចហើយ ។ [redacted] មុន្នី បានទៅរស់នៅភូមិផ្សេងហើយក៏មិនដែលត្រឡប់មករស់នៅវិញដែរចំណែកឯកូនរបស់ [redacted] មុន្នី គឺឈ្មោះ [redacted] សុបញ្ញា គឺបានមករស់នៅជាមួយខ្លួន តែមករស់នៅក្នុងឆ្នាំណា គឺខ្លួនមិនចាំទេ ។ ចំពោះឈ្មោះ [redacted] សុបញ្ញា មករស់នៅជាមួយខ្លួនគឺខ្លួនបានជួលឱ្យមកធ្វើចំការអោយ និងរស់នៅគ្រាន់បានជាគ្នាតែប៉ុណ្ណោះ។ បញ្ហាដែលខ្លួនចេញពីផ្ទះនោះគឺ ខ្លួនមកព្យាបាលជម្ងឺ ។

២-២.សហចុងចម្លើយឈ្មោះ [redacted] មន្នី បានអះអាងថាខ្លួនបានរស់នៅជាមួយ ឈ្មោះ [redacted] សម្បត្តិ តាំងពីឆ្នាំ១៩៧៩ ជាមួយតាម៉ឹង យាយអ៊ំ ជាបងប្អូនគាត់តែឪពុកខ្លួនបានស្លាប់ហើយ ។ ពេលនោះគឺរដ្ឋថាអ្នកណាចាប់បានប៉ុណ្ណាយកប៉ុណ្ណឹងទៅហើយពេលនោះខ្លួនអាយុប្រហែល ១៥ឆ្នាំហើយ ។ តែពេលនៅឪពុកខ្លួនមិនបានរស់នៅលើដីទំនាស់នេះទេខ្លួនបានមករស់នៅឯស្រែជាមួយឈ្មោះ [redacted] សម្បត្តិ ហើយខ្លួនបានការប្រពន្ធនៅឆ្នាំ ១៩៨៧ទៅនៅភូមិផ្សេងហើយការរស់នៅលើដីនេះពុំមានលិខិតស្នាមអ្វីទេតែដោយខ្លួនយល់ថាគាត់ជាមីង ។ ខ្លួនមិនបានធ្វើប័ណ្ណដីទេ ព្រោះកាលនោះមិនមានគេចុះទៅធ្វើទេ ។ ខ្លួនរស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ តាំងពីឆ្នាំ ១៩៧៩ តែមិនបានចុះឈ្មោះនៅក្នុងប័ណ្ណគ្រួសារទេ ។ រដ្ឋចែកដីឱ្យនៅឆ្នាំ ១៩៨០ គឺពេលនោះខ្លួនអាយុ



Scanned with CamScanner

ប្រហែល ១៤ឆ្នាំ តែឱ្យតែអ្នកនៅសុទ្ធតែមានរបបទាំងអស់ ។ ក្នុងឆ្នាំ១៩៨៧ ដែលខ្លួនទៅរស់នៅជាមួយប្រពន្ធ គឺដីរដ្ឋចែកឱ្យសុទ្ធ ។ សហចុងចម្លើយឈ្មោះ [redacted] សុបញ្ញា បានអះអាងបន្ថែមទៀតថាខ្លួនមករស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ នេះគឺគាត់បានសុំខ្លួនឱ្យមករស់នៅជាមួយគាត់ តែខ្លួនមិនទាន់មានប្រពន្ធទេ ។ ចំពោះចំណែកដីនេះគឺខ្លួនគ្មានទេ គឺចាស់ៗបានមាន ។

តាមការអះអាងរបស់ដើមចោទ និងសហចុងចម្លើយអំពីអង្គហេតុដែលខ្លួនគ្រប់គ្រងគប្បីតុលាការលើកយកភស្តុតាងមកបញ្ជាក់ ។

៣-ការពិនិត្យភស្តុតាង៖

៣-១.ភស្តុតាងជាឯកសារមានដូចខាងក្រោម៖

_សៀវភៅគ្រួសាររបស់ឈ្មោះ [redacted] សម្បត្តិ № ០៩.៥៣១៣ ក.ណ ដែលបានធ្វើនៅសាលាឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល បានបញ្ជាក់ថាពិតជាគ្មានឈ្មោះរបស់សហចុងចម្លើយនៅក្នុងសៀវភៅគ្រួសារទេ ដូច្នេះអាចបញ្ជាក់បានថាសហចុងចម្លើយគឺពិតជាមិនមែនជាសមាជិកគ្រួសាររបស់ដើមចោទឈ្មោះ [redacted] សម្បត្តិ ទេ ។

_បានឃើញសៀវភៅស្នាក់នៅនាមត្រកូល-នាមខ្លួន [redacted] សម្បត្តិ លេខ ០០៦.១២៣៨ គឺមិនមានឈ្មោះសហចុងចម្លើយនៅក្នុងសៀវភៅស្នាក់នៅទេដូច្នេះអាចបញ្ជាក់បានថាសហចុងចម្លើយគឺគ្រាន់តែមកស្នាក់នៅជាមួយដើមចោទឈ្មោះ [redacted] សម្បត្តិ បណ្តោះអាសន្នតែប៉ុណ្ណោះ ។

_បានឃើញលិខិតបញ្ជាក់ពីប្រវត្តិដីធ្លីលេខ ៣៥៨/១៩ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានបណ្តោយប្រវែង ១៦០ម៉ែត្រ និងទទឹងប្រវែង ២៧,៧ម៉ែត្រ មានទំហំផ្ទៃក្រឡាសរុប ៤៥៩២ម៉ែត្រការ៉េ ពិតជាដីរបស់ឈ្មោះ [redacted] សម្បត្តិ ភេទស្រី អាយុ ៧៧ឆ្នាំ ដែលបានកាន់កាប់លើដីនេះតាំងពីឆ្នាំ១៩៨០ នៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ពិតប្រាកដមែន ។

៣.២.ភស្តុតាងជាសាក្សីឆ្លងតាមការសាកសួរសាក្សីឃើញថា៖

៣.២.១.សាក្សីឈ្មោះ [redacted] សុផល បានឆ្លើយថា៖ខ្លួនធ្វើជាមេឃុំនៅឆ្នាំ២០០៧ ចំពោះប្រវត្តដីនេះ គឺខ្លួនស្គាល់តែទីតាំងដីទេចំពោះដើមចោទដែលរស់នៅលើដីនេះពីឆ្នាំណានោះគឺខ្លួនមិនច្បាស់ទេ ប៉ុន្តែដឹងថាជាដីរបស់ឈ្មោះ [redacted] សម្បត្តិ។ ហើយចំពោះឈ្មោះ [redacted] មុន្នី ប្រហែលជាមានចំណែកដីក្នុងនោះដែរក្នុងរបបរដ្ឋកម្ពុជាក្នុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ។ តែចំពោះរបបគឺរដ្ឋចែកក្នុងឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០ ដោយគិតតាមជាក់ស្តែងដោយក្នុងនោះគាត់បានតែម្នាក់ ២ម៉ែត្រទេ ។ ចំពោះដីលំនៅដ្ឋាននេះខ្លួនមិនច្បាស់ថាឈ្មោះ [redacted] មុន្នី ទទួលបានដីលំនៅដ្ឋានឬក៏ដីប្រាំងទេ ។ តាំងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១០ គឺឈ្មោះ [redacted] មុន្នី រស់នៅលើដីនេះគឺខ្លួនមិនច្បាស់ទេតែឈ្មោះ [redacted] សម្បត្តិ គាត់រស់នៅលើដីនេះរហូត ។ ចំពោះដីនេះគឺជារបស់ឈ្មោះ [redacted] សម្បត្តិ ពិតជាម្ចាស់កម្មសិទ្ធិពិតប្រាកដមែន ។ ចំពោះដីនេះមានរបបរបស់ឈ្មោះ [redacted] មុន្នី ឬអត់ខ្លួនមិនច្បាស់ទេ ។ ហើយលិខិតផ្ទេរកម្មសិទ្ធិ តែក្រោយមកបានធ្វើការបដិសេធចោលវិញដោយមានការស្នើសុំពីឈ្មោះ [redacted] សម្បត្តិ និងស្មៀនធ្វើមិនច្បាស់លាស់ ។

៣.២.២.សាក្សីឈ្មោះ [redacted] បូរ បានឆ្លើយថា៖ ខ្លួនជាមេភូមិរងតាំងពីឆ្នាំ២០០៣ រហូតដល់បច្ចុប្បន្នខ្លួនស្គាល់គាត់ទាំងពីរនាក់ ហើយពួកគាត់ឈ្លោះគ្នារឿងដីធ្លី ។ ចំពោះដីនេះគឺជារបស់ឈ្មោះ [redacted] សម្បត្តិ ហើយឈ្មោះ [redacted] មុន្នី គឺគ្រាន់តែមករស់នៅជាមួយគាត់ ។ ចំពោះរបបដីនេះគឺខ្លួនមិនដឹងទេ គឺគ្រាន់តែដឹងថាឈ្មោះសោម មុន្នី មករស់នៅជាមួយឈ្មោះ [redacted] សម្បត្តិ តែប៉ុណ្ណោះ ។

៣.២.៣.សាក្សីឈ្មោះ [redacted] យន បានឆ្លើយថា៖ ដីនេះជារបស់ខ្លួននិងប្អូនខ្លួនតែក្រោយមកខ្លួនបានប្រគល់ដីនេះឱ្យទៅប្អូនរបស់ខ្លួនឈ្មោះ [redacted] សម្បត្តិ ហើយឈ្មោះ [redacted] មុន្នី គឺគ្រាន់តែបានមកនៅទេពុំមាន

ឈ្មោះក្នុងបញ្ជីទេ ។

៣.២.៤.សាក្សីឈ្មោះ [redacted] សុជាតិ បានឆ្លើយថា:ខ្លួនត្រូវជាក្មួយបង្កើតរបស់ឈ្មោះ [redacted] សម្បត្តិ ចំពោះដីនេះជាដីរបស់ឈ្មោះ [redacted] សម្បត្តិ ។ ពេលយាយមកនៅភ្នំពេញគឺព្រោះយាយឈឺ ហើយមូលហេតុយាយចុះចេញពីផ្ទះគឺដោយសារចៅគាត់ចាក់បាស់រំខាន ។ កាលពីមុនឈ្មោះ [redacted] សុបញ្ញា គឺជាអ្នករស់នៅជាមួយយាយ ។

៣.២.៥.សាក្សីឈ្មោះ [redacted] យ៉ន បានឆ្លើយថា:ខ្លួនត្រូវជាប្អូនឈ្មោះ [redacted] សម្បត្តិ ប្រវត្តដីនេះគឺជារបស់ក្រុមគ្រួសារខ្លួន ហើយបានប្រគល់ដីនេះឱ្យទៅឈ្មោះ [redacted] សម្បត្តិ ដែលគាត់ជាអ្នកមើលថែ ឪពុកម្តាយ ចំពោះឈ្មោះ [redacted] មុន្នី ពុំមានចំណែកទេ ។ [redacted] មុន្នី បានរៀបការប្រពន្ធហើយចាកចេញនៅឆ្នាំ១៩៨៧ តែចំពោះឪពុកម្តាយឈ្មោះ [redacted] មុន្នី ពេលបែកឆ្នាំ១៩៧៩ គាត់បានមករស់នៅក្រោយគេ ទើបឈ្មោះ [redacted] សម្បត្តិ បានចែកដីឱ្យទៅនៅភូមិផ្សេង ។

៣.២.៦.សាក្សីឈ្មោះ [redacted] លាភ បានឆ្លើយថា:ខ្លួនជាប្អូនជាដូនមួយរបស់ឈ្មោះ [redacted] សម្បត្តិ ហើយដីទំនាស់នេះជារបស់ឈ្មោះ [redacted] សម្បត្តិ ហើយ [redacted] មុន្នី គ្រាន់តែមករស់នៅជាមួយ ។ ចំពោះការចែកដីរបបដែលរដ្ឋចែកនេះគឺខ្លួនមិនបានដឹងទេ ។

៣.២.៧សាក្សីឈ្មោះ [redacted] ដារ៉ា បានឆ្លើយថា: ដីនេះគឺជារបស់ឈ្មោះ [redacted] សម្បត្តិ តែក្រោយមកក្មួយបានមករស់នៅជាមួយ ។ ចំពោះឈ្មោះ [redacted] មុន្នី មានរបបឬអត់គឺខ្លួនអត់ដឹងទេ ព្រោះខ្លួនធ្វើជាមេភូមិឆ្នាំ ១៩៩២ ហើយមេភូមិមុនមិនមានឯកសារទេតែខ្លួនបានរស់នៅក្នុងភូមិនេះតាំងពីឆ្នាំ១៩៩០ ។

៣.២.៨.សាក្សីឈ្មោះ [redacted] ថៃ បានឆ្លើយថា:ខ្លួនមានអាយុ ៧០ឆ្នាំ ខ្លួនស្គាល់អ្នកទាំងអស់គ្នាតែពុំជាប់សាច់ញាតិទេ ចំពោះដីនេះគឺជារបស់ឈ្មោះ [redacted] សម្បត្តិ តែ [redacted] មុន្នី គ្រាន់តែជាក្មួយនៅជាមួយ សោម សម្បត្តិ ។ ចំពោះរបបដីនេះដោយពេលនោះឈ្មោះ [redacted] សម្បត្តិ បានប្រគល់ដី ២៩ម៉ែត្រ នោះ តែក្រោយមក [redacted] សម្បត្តិ មិនព្រមផ្តិតមេដៃវិញដោយយល់ថា [redacted] មុន្នី ពានលាក់លិខិតប័ណ្ណដីមូលហេតុដែល [redacted] សម្បត្តិ ថាប្រគល់ដីឱ្យ [redacted] មុន្នី ដោយយល់ថា [redacted] មុន្នី ធ្លាប់នៅជាមួយ ។ បញ្ហាប្រគល់ដី ២៩ម៉ែត្រ នេះគឺបញ្ហាវាស់វែងដីខ្លួនបានចូលរួមតែមេភូមិបានធ្វើលិខិតតែឈ្មោះ [redacted] សម្បត្តិ ពុំទាន់ផ្តិតមេដៃទេ ។

៣.២.៩.សាក្សីឈ្មោះ [redacted] សាវិន បានឆ្លើយថា: ខ្លួនបានស្គាល់ពួកគាត់ ហើយពួកគាត់ឈ្លោះគ្នារឿង ដី តែដីនេះខ្លួនដឹងថាជារបស់ឈ្មោះ [redacted] សម្បត្តិ ។ ចំពោះបញ្ហារបបដីនោះគឺរបបឪពុកម្តាយគឺជារបបទី១ ចំពោះដីផ្ទះគឺជាពីមុន ។

៣.២.១០.សាក្សីឈ្មោះ [redacted] សារី បានឆ្លើយថា:ខ្លួនដឹងថាដីនេះជារបស់ឈ្មោះ [redacted] សម្បត្តិ ។ ចំពោះប្រវត្តិដីនេះ ខ្លួនពុំបានដឹងទេ ។

៤.ផ្អែកតាមចំណុចទី២ និងទី៣ នៃផ្នែកសំអាងហេតុនេះ តុលាការអាចជឿបានថាដីដែលមានទំហំបណ្តោយប្រវែង ១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រដែលស្ថិតនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល គឺពិតជាកម្មសិទ្ធិរបស់ដើមចោទពិតប្រាកដមែន គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ ។

៥.ផ្អែកតាមចំណុចទី៤ ដោយផ្អែកលើសិទ្ធិជាម្ចាស់កម្មសិទ្ធតាមបញ្ញត្តិមាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយរុះរើចេញនូវទ្រព្យសម្បត្តិទាំងឡាយណាដែលជាកម្មសិទ្ធិរបស់សហចុងចម្លើយចេញពីទីតាំងដីខាងលើដែលជាកម្មសិទ្ធិរបស់ដើមចោទ ។



Scanned with CamScanner

៦.ការទាមទាររបស់ដើមចោទសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ន គប្បីតុលាការធ្វើការពិចារណានិងសម្រេច ។

៧.ដើមចោទទាមទារឱ្យសហចុងចម្លើយ សងសំណងជម្ងឺចិត្ត៥០.០០០.០០០លានរៀល(ហាសិបលានរៀល)តុលាការយល់ឃើញថាការខូចខាតពិតជាកើតមានឡើងដោយសារអំពើរបស់ចុងចម្លើយពិតមែន ប៉ុន្តែគប្បីតុលាការធ្វើការពិចារណានិង សម្រេចទទួលស្គាល់តែផ្នែកណាមួយប៉ុណ្ណោះ ។

៨.ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តីតុលាការនិងសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ឈ្មោះ [redacted] សម្បត្តិ ជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះដែលមានទីតាំងនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ដែលមានទំហំទើបនិងវាស់ទីតាំងតាមក្រោយដែលមានបណ្តោយប្រវែង១៦០ម៉ែត្រ និងទទឹងប្រវែង ២៨,៧ម៉ែត្រ មានទំហំផ្ទៃក្រឡាសរុប ៤៥៩២ម៉ែត្រលការ៉េ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុបញ្ញា,ឈ្មោះ [redacted] មុន្នី(ម៉ឹង មុន្នី) និងឈ្មោះ [redacted] ស្រី រុះរើសម្ភារៈចេញពីលើទីតាំងដី និងផ្ទះខាងលើនៅភូមិកំពង់រទេះ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ។

៣-ច្រានចោលការសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

៤-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុបញ្ញា,ឈ្មោះ [redacted] មុន្នី( [redacted] មុន្នី) និងឈ្មោះ [redacted] ស្រី សងសំណងជម្ងឺចិត្តចំនួន ១០លានរៀល(ដប់លានរៀលគត់) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្បត្តិ តាមការទាមទារលើសពីនេះបដិសេធចោល ។

៥-ប្រាក់ប្រដាប់ក្តីនេះជាបន្ទុករបស់ចុងចម្លើយ ។

_សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ។

ទុកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឯកស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner